# ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ជួបប្រធានមូលនិធិបង្ការរបួសអាស៊ី



នៅព្រឹកថ្ងៃទី១៩ ខែ សីហា ឆ្នាំ២០១៤ ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និង សិប្បកម្ម បានទទួលជួបជាមួយលោក **Greig Craft** ប្រធានមូលនិធិបង្ការរបួសអាស៊ី និងសហការី ដើម្បីពិភាក្សាការងារ នៅទីស្តីការក្រសួង ។



លោក **Greig Craft** ប្រធានមូលនិធិបង្ការរបួសអាស៊ី (Asia Injury Prevention Foundation) បានមានប្រសាសន៍ជម្រាបជូនពីគោលបំណងនៃជំនួបពិភាក្សា ដោយផ្តោតការយកចិត្តទុកដាក់ទៅលើការប្រើប្រាស់មួកសុវត្ថិភាពស្របតាមស្តង់ដា សម្រាប់អ្នកធ្វើចរាចរណ៍តាមដងផ្លូវសាធារណៈ ជាពិសេសអ្នកបញ្ជាទោចក្រយានយន្ត និងអ្នកជិះខាងក្រោយ រួមទាំងកូន ក្មេងផងដែរ ។ លោក **Greig Craft** បានបន្ថែមថាៈ មូលនិធិបង្ការរបួសអាស៊ី គឺជាអង្គការមិន

ស្វែងរកប្រាក់ចំណេញ ទទួលបានការសហការគាំទ្រពីអង្គការអន្តរជាតិ តំណាងស្ថានទូត និងដៃគូក្រុមហ៊ុនមួយចំនួន ដូចជា៖ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) –ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិសហរដ្ឋអាមេរិក (USAID) –ស្ថានទូតស៊ុីស–ស្ថានទូតដាណឺម៉ាក – ក្រុមហ៊ុន Chevron –ក្រុមហ៊ុន FedEX –ក្រុមហ៊ុន Manulife និងក្រុមហ៊ុន Johnson& Johnson ជាដើម ។ អង្គការបានធ្វើសកម្មភាព ជាច្រើនប្រទេសក្នុងតំបន់អាស៊ី ដែលមានកម្មវិធីជាគោលដៅសំខាន់គឺ៖ការប្រើប្រាស់មួកសុវត្ថិភាព ដែលមានកំរិតស្តង់ដា–កិច្ចការពារអ្នកដំណើរឆ្លងផ្លូវ និងសុវត្ថិភាពជាទូទៅតាមដងផ្លូវ ។ ក្នុងជំនួបនាថ្ងៃនេះ លោកប្រធានក៏បានបង្ហាញពីជំហររបស់អង្គការលោក ក្នុងការសហការគាំទ្រពីតម្រូវការរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្មផងដែរ ។



ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានសម្តែងការស្វាគមន៍ និងវាយតម្លៃខ្ពស់ចំពោះមូលនិធិបង្ការរបួសអាស៊ី ដែលបានធ្វើកិច្ចការយ៉ាងសកម្ម ជាមួយរាជរដ្ឋាភិបាល ក៏ដូចជាដៃគូរពាក់ព័ន្ធ ទាក់ទងដល់សុវត្ថិភាពចរាចរណ៍តាមដងផ្លូវ–ការពាក់មួកសុវត្ថិភាព រួមទាំងការងារសង្គម ដូចជា ការចែកមួកសុវត្ថិភាព និងការផ្សព្វផ្សាយការយល់ដឹងជាសាធារណៈដល់ សិស្ស និស្សិត និងសាធារណៈជនផងដែរ ។ ឯកឧត្តម ទេសរដ្ឋមន្ត្រី បានបញ្ជាក់ថា៖ រាជរដ្ឋាភិបាល បានយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះសុវត្ថិភាពចរាចរណ៍ ដែលបានយាយីជីវិត បង្កឱ្យមានការស្លាប់ របួស ពិការ ដែលជាបន្ទុកដ៏ធ្ងន់ធ្ងរសម្រាប់ក្រុមគ្រួសារ សង្គម និងធ្វើឱ្យប៉ះពាល់ដល់ការរីកចម្រើនផ្នែកសេដ្ឋកិច្ចផងដែរ ។ ចេញពីហេតុផលនេះ រាជរដ្ឋាភិបាល ជាបន្តបន្ទាប់ បានធ្វើវិសោធនកម្មក្នុងមាត្រាមួយចំនួននៃច្បាប់ចរាចរណ៍ ហើយប្រហែលជានៅខែក្រោយសេចក្តីព្រាងស្តីពីច្បាប់ចរាចរណ៍ថ្មី នឹងដាក់ឆ្លងការអនុម័តពីរដ្ឋសភាហើយ ។

ទាក់ទងនិងការប្រើប្រាស់មួកសុវត្ថិភាព ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានឯកភាពចំពោះមតិ របស់លោកប្រធានមូលនិធិបង្ការរបួសអាស៊ី ដែលបានបញ្ជាក់ថា៖ការប្រើប្រាស់មួកមួយចំនួនធំ មិនទាន់ស្របតាមស្តង់ដា និងមានមួកខ្លះ គឺជាមួកផលិតក្លែងក្លាយ ដែលមិនអាចការពារសុវត្ថិភាពដល់អ្នកប្រើប្រាស់ឱ្យបានដល់កំរិតអតិបរមាបានឡើយ ។ ទាក់ទងបញ្ហានេះ ឯកឧត្តម ទេសរដ្ឋមន្ត្រី បានបញ្ជាក់ថា៖ក្រុមប្រឹក្សាស្តង់ដាជាតិកម្ពុជា បានសម្រេចនូវស្តង់ដា

ចំនួន១០ ដែលបានអនុម័តរួចជាស្តង់ដារជាតិ ត្រូវបានកំណត់ជាស្តង់ដារបញ្ជា ដើម្បីអនុវត្តជាចាំបាច់សម្រាប់ការធានាដល់សុខភាព សុវត្ថិភាព និងអាយុជីវិតរបស់អ្នកប្រើប្រាស់ ។ ក្នុងនោះ គឺមានស្តង់ដាបញ្ជាសម្រាប់មួយសុវត្ថិភាពផងដែរ ។

ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានស្នើឱ្យលោក **Greig Craft** ប្រធានមូលនិធិបង្ការរបួសអាស៊ី និងសហការី អញ្ជើញចុះពិនិត្យជាក់ស្តែង នៅវិទ្យាស្ថានស្តង់ដាកម្ពុជា របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅថ្ងៃបន្ទាប់ ដើម្បីពិនិត្យលទ្ធភាពជួយលើផ្នែកណាខ្លះ**?** ជាពិសេស គឺការបំពាក់ឧបករណ៍ពិសោធន៍ធ្វើតេស្ត លើមួកសុវត្ថិភាព ដើម្បីឱ្យប្រាកដថា**:** មួកនោះផលិតស្របតាមកំរិតស្តង់ដាត្រឹមត្រូវ ដោយមានការទទួលស្គាល់ពីវិទ្យាស្ថានស្តង់ដាកម្ពុជា មុននិងអនុញ្ញាតឱ្យធ្វើការនាំចូល និងចែកចាយលើទីផ្សារ ពីព្រោះមួយសុវត្ថិភាពត្រូវបានកំណត់ជាស្តង់ដាបញ្ជាហើយ ។

ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានថ្លែងអំណរគុណផងដែរ ដល់មូលនិធិបង្ការរបួសអាស៊ី ដែលនឹងទទួលមន្ត្រីកម្ពុជាចំនួនពីររូប ពីវិទ្យាស្ថានស្តង់ដាកម្ពុជា ដើម្បីចូលរួមធ្វើកម្មសិក្សានៅប្រទេសវៀតណាម នាពេលខាងមុខ ។